# បាឋកថា / TALK

## លោហកម្មនៃចក្រភពខ្មែរ ៖

## ស្ថានីយ៍ស្ល៍ដែកមួយប្រទះឃើញនៅអតីតរាជធានីអង្គរ

## Metallurgy of the Khmer Empire: discovery of an iron smelting site in Angkor capital

*ជាភាសាខ្មែរ ដោយលោក អ៊ឹម សុខរិទ្ធី* / in Khmer, with English subtitle on slide by Im Sokrithy



ថ្ងៃសុក្រ ទី៧ ខែកក្កដា ឆ្នាំ២០១៧ ម៉ោង៥:៣០ល្ងាច

នៅសាលសម្តែងក្នុងមហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

Friday, July 7, 2017, 5:30pm at RUFA (behind the National Museum)

**សូមអញ្ជើញចូលរួមស្តាប់ដោយមេត្រី**

---

*វិភាគទានពី* with contribution from

- o សប្បុរសជន
- o សមាជិកយសោធរ
- o មិត្តយសោធរ

- o Individuals
- o Members of Yosothor
- o Friends of Yosothor

Yosothor@gmail.com www.yosothor.org

# លោហកម្មនៃចក្រភពខ្មែរ ៖
# ស្ថានីយ៍ស្លដែកមួយប្រទះឃើញនៅអតីតរាជធានីអង្គរ

*ដោយលោក អ៊ឹម សុខរិទ្ធី*

*នាពេលថ្មីៗកន្លងមកនេះ អ្នកស្រាវជ្រាវនៃអាជ្ញាធរអប្សរាបានប្រទះឃើញកន្លែងស្លដែកមួយស្ថិតនៅភូមិសាលាក្រវ៉ាន់ (ក្នុងតំបន់២នៃបរិវេណបេតិកភណ្ឌពិភពលោក) ដែលមិនអាចមើលឃើញទេតាមរយៈរូបថតពីលើយន្តហោះឬក៏តាម Radar។ ដោយសារមានអាចម៍ដែកនៅរាយប៉ាយលើនោះ អ្នកស្រុកក៏ឲ្យឈ្មោះថា «ទួលអាចម៍ដែក»។ ម្យ៉ាងទៀតគេក៏ឃើញមានបំណែកកុលាលភាជន៍លាយឡំគ្នានៅត្រង់នោះដែរ។ ឯពីមុននោះបន្តិចទៅទៀត យើងធ្លាប់ប្រទះឃើញ ហើយធ្លាប់ធ្វើកំណាយចង្ក្រានស្លដែករបៀបនេះនៅជាយរាជធានី ពោលគឺប្រមាណ៦០គ.ម. ពីមណ្ឌលក្រុង ដូចជានៅភូមិខ្វាវ (ខាងកើត) និងភូមិគោល (ខាងពាយព្យ) ជាដើម។ ប៉ុន្តែបើពោលពីមណ្ឌលរាជធានីតែម្តង នេះជាលើកទីមួយហើយដែលយើងប្រទះឃើញចង្ក្រានស្លដែក។ យ៉ាងណាក៏ដោយ ការដែលធ្លាប់យល់ឃើញពីមុនមកថា ដែកប្រើប្រាស់នៅអង្គរសុទ្ធសឹងគេនាំយកមកពីទីឆ្ងាយ ដូចជាតំបន់បន្ទាយបាកាន្ត, តំបន់ភ្នំដែក ឬរហូតដល់តំបន់បុរីរម្យទៀតផងនោះ ឥឡូវនេះត្រូវសើរើពិចារណាជាថ្មីឡើងវិញ។*

*នៅដើមឆ្នាំ២០១៦និងដើមឆ្នាំ២០១៧ យើងបានធ្វើកំណាយនៅភូមិសាលាក្រវ៉ាន់ដែលពោលមកខាងលើនេះ។ រីឯបាឋកថារបស់ខ្ញុំ គឺធ្វើឡើងក្នុងបំណងរាយការណ៍លទ្ធផលកំណាយនេះឯង។*

# Metallurgy of the Khmer Empire:
# Discovery of an iron smelting site in Angkor capital

by Im Sokrithy

In these recent years, researchers from the Apsara Authority came across evidences of an ancient iron smelting site, in Sala Kravan village (Zone 2 of the Angkor World Heritage site) which could not be seen in aerial photographs nor be detected by radar. Iron slags left on the mounds made local people called the site *Tuol Ach Daek*, or "mound of slags". Many ceramics pieces remain on the sites as well. We previously knew about the existence of some iron sites, located at far suburban areas of the capital, such as Khvav (east) and Kôl (north-west). But as for the heart of Angkor, this is a very first discovery. Unexpected until then for the capital city center as well as its fringes, these recent discoveries require that all the assumptions about the importation of iron from Bakan, Phnom Dek area, Buriram, etc. be reassessed.

Early 2016 and early 2017, two excavation campaigns have been conducted at Sala Kravan, the results of which will be reported in my presentation.